# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ឧត្តមក្រុមប្រឹក្សា កំណែទម្រង់រដ្ឋ**
**ក្រុមប្រឹក្សា កំណែទម្រង់រដ្ឋបាល**
**លេខ: ០២៦/ សសក**

លេខ 6072
ថ្ងៃទី 27 ខែ 11 ឆ្នាំ២០០៧

ថតចម្លង
នាយកដ្ឋាន.រដ្ឋបាល.

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសម្រាប់រៀបចំគោលការណ៍ នីតិវិធី និងបែបបទ សម្រាប់ការប្រឡងផ្ទៃក្នុងដើម្បីប្តូរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

---

## ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ១១ សរណន ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ ស្តីពីការផ្អាកជាបណ្តោះអាសន្ននូវរាល់ការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល



ទីស្នាក់ការស្ថិតនៅ ទីស្តីការគណៈរដ្ឋមន្ត្រី (អគារខាងលិច) មហាវិថីសហព័ន្ធរុស្ស៊ី រាជធានី ភ្នំពេញ

- យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួង ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩

## សម្រេច

**ប្រការ១ :** ត្រូវបានបង្កើតក្រុមការងារចំនួន ៤ សម្រាប់រៀបចំគោលការណ៍ នីតិវិធី និងបែបបទសម្រាប់ប្រឡងផ្ទៃក្នុង ដើម្បីប្តូរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ដូចមានខាងក្រោម :

ក្រុមការងារទី១ : ធ្វើការសិក្សា និងលើកយោបល់អំពីការកំណត់ស្តង់ដារពិន្ទុតាមប្រភេទក្របខ័ណ្ឌនីមួយៗ និងកំណត់ចំនួនមុខតំណែងទំនេរ នៃក្របខ័ណ្ឌនីមួយៗសម្រាប់ការប្រឡងប្រជែងប្តូរក្របខ័ណ្ឌ ។

ក្រុមការងារនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | អ្នកសម្របសម្រួលរួម |
| - តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងក្រសួងកិច្ចការនារី | សមាជិក |

**ក្រុមការងារទី២ :** សិក្សា និងលើកយោបល់អំពីការរកដំណោះស្រាយ ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃសញ្ញាប័ត្រសម្រាប់ការប្រឡងប្រជែងប្តូរក្របខ័ណ្ឌ ។

ក្រុមការងារនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - តំណាងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | អ្នកសម្របសម្រួលរួម |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| - តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងកិច្ចការនារី | សមាជិក |
| - តំណាងរាជបណ្ឌិតសភាកម្ពុជា | សមាជិក |
| - តំណាងក្រសួង ស្ថាប័ន ដែលមានសាលាបណ្តុះបណ្តាល | សមាជិក |

ក្រុមការងារទី៣ : សិក្សា និងលើកយោបល់អំពីការរកដំណោះស្រាយ និងមធ្យោបាយសម្រាប់មន្ត្រីក្រមការដែលចេញពីសាលាភូមិន្ទរដ្ឋបាល ហើយមានសញ្ញាប័ត្រចាប់ពីបរិញ្ញាប័ត្រឡើងទៅ និងមន្ត្រីសកម្មការងារ ដែលពុំមានពេលវេលាគ្រប់គ្រាន់ទៅរៀនយកសញ្ញាប័ត្រខ្ពស់សម្រាប់ចូលរួមប្រឡងប្រជែងដើម្បីប្តូរក្របខ័ណ្ឌ ។

ក្រុមការងារនេះ មានសមាសភាពដូចខាងក្រោម :

- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី — អ្នកសម្របសម្រួលរួម
- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ — សមាជិក
- តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ — សមាជិក
- តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល — សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- តំណាងក្រសួងមហាផ្ទៃ — សមាជិក
- តំណាងក្រសួងកិច្ចការនារី — សមាជិក
- តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ — សមាជិក

ក្រុមការងារទី៤ : សិក្សា និងលើកយោបល់លើការរៀបចំយន្តការ នីតិវិធី និងបែបបទស្តង់ដាតែមួយសម្រាប់ការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរក្របខ័ណ្ឌឱ្យមានស្តង់ដាគុណភាពខ្ពស់ ។

ក្រុមការងារនេះ មានសមាសភាពដូចខាងក្រោម :

- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី — អ្នកសម្របសម្រួលរួម
- តំណាងក្រសួងអប់រំ យុវជន និងកីឡា — សមាជិក
- តំណាងសាលាភូមិន្ទរដ្ឋបាល — សមាជិក
- តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ — សមាជិក
- តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល — សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- តំណាងក្រសួងកិច្ចការនារី — សមាជិក
- តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ — សមាជិក

**ប្រការ២** : ក្រុមការងារនីមួយៗ មានភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ និងស្វែងយល់ឱ្យបានស៊ីជម្រៅទៅលើប្រធានបទរបស់ខ្លួន
- សិក្សាស្វែងយល់ទៅលើលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធទៅនឹងប្រធានបទនីមួយៗ
- ប្រជុំពិនិត្យ ពិភាក្សា ផ្តល់យោបល់ និងរៀបចំជាសេចក្តីព្រាង គោលការណ៍ នីតិវិធី និងបែបបទជា

ស្តង់ដាគំរូទៅតាមប្រធានបទនីមួយៗ

- បញ្ជូនលទ្ធផលនៃកិច្ចប្រជុំ មតិយោបល់ និងសេចក្តីព្រាងគោលការណ៍ នីតិវិធី និងបែបបទសម្រាប់ការអនុវត្តទៅអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីរៀបចំចងក្រងជាគោលការណ៍រួមសម្រាប់ដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង និងលើកយោបល់ស្នើសុំការពិនិត្យនិងសម្រេចពីថ្នាក់ដឹកនាំ ។

**ប្រការ៣ :** សមាជិកនៃក្រុមការងារនីមួយៗ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់តំណាងក្រសួង ស្ថាប័ន ដែលជាអ្នកសម្របសម្រួលរួមតាមក្រុមនីមួយៗរៀងៗខ្លួន ។

**ប្រការ៤ :** ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់បញ្ជូនឈ្មោះមន្ត្រីតំណាងរបស់ខ្លួន ដើម្បីចូលរួមតាមក្រុមនីមួយៗ មកអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**ប្រការ៥ :** សេចក្តីសម្រេចនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 24 ខែ 11 ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ទី១ជា ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ១
- ឯកសារ-កាលប្បវត្តិ